# ឯកសារគោលគំនិតសម្រាប់សំរាប់គំរោងឥណទាន

ឧបសម្ព័ន្ធនេះរួមមានឯកសារគោលគំនិតសម្រាប់ផលិតផលផ្តល់ឥណទានដែលត្រូវបានគ្រោងទុកៈ

(i) តារាង ក៤.១: គម្រោងផ្គត់ផ្គង់ទឹកនិងអនាម័យនៅជនបទ

(ii) តារាង ក៤.២: កម្មវិធីវិស័យហិរញ្ញវត្ថុ (កម្មវិធីរងទី ៣)

(iii) តារាង ក៤.៣: ជីវភាពប្រកបដោយនិរន្តភាពនៅតំបន់បឹងទន្លេសាប

(iv) តារាង ក៤.៤: គម្រោងទប់ស្កាត់ជម្ងឺឆ្លងនៃ GMS

(v) តារាង ក៤.៥: គម្រោងកែលំអរបរិស្ថាននៅចុងឃ្នាស

## តារាង ក៤.១: គម្រោងផ្គត់ផ្គង់ទឹក និងអនាម័យនៅជនបទ

## ឯកសារគោលគំនិត

**កាលបរិច្ឆេទ:** ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០០៤

**១. ប្រភេទ/ទម្រង់នៃជំនួយ**

☒ ប្រភេទកម្ចីឥណទាន

- ☐ ឥណទានគម្រោង
- ☐ ឥណទានកម្មវិធីកំណែទម្រង់
- ☒ ឥណទានវិស័យ
- ☐ ឥណទានកម្មវិធីអភិវឌ្ឍន៍វិស័យ
- ☐ ផ្សេងទៀត:

☒ ប្រភេទមិនមែនជាកម្ចីឥណទាន

- ☒ សំរាប់ត្រៀមរៀបចំគម្រោង
- ☐ ក្រៅពីសំរាប់ត្រៀមរៀបចំគម្រោង
  - ☐ ការងារផ្នែកសេដ្ឋកិច្ច ប្រធានបទ និង វិស័យ
  - ☐ កិច្ចអភិវឌ្ឍន៍ស្ថាប័ន
  - ☐ ផ្សេងទៀត:

**២. មុខព្រួញជំនួយ**

ក. ប្រសិនបើជំនួយផ្តោតលើវិស័យឬអនុវិស័យជាក់លាក់មួយ ចូរបញ្ជាក់

វិស័យ: ផ្គត់ផ្គង់ទឹក អនាម័យ និង ការគ្រប់គ្រងសំណល់

អនុវិស័យ:

ខ. សម្រាប់ការត្រៀមរៀបចំគម្រោង និងការផ្តល់ឥណទាន ចំណាត់ថ្នាក់

- ☐ អន្តរាគមន៍មានមុខព្រួញ
- ☒ អន្តរាគមន៍ទូទៅ

គ. វិស័យប្រធានបទសំខាន់ៗ

| |
|---|
| ប្រធានបទ<br>☐ កំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព ☒ ចីរភាពបរិស្ថាន<br>☒ កិច្ចអភិវឌ្ឍន៏សង្គមរួម ☐ កិច្ចសហប្រតិបត្តិការតំបន់<br>☐ អភិបាលកិច្ច ☐ កិច្ចអភិវឌ្ឍន៏វិស័យឯកជន<br>☒ យេនឌ័រនិងកិច្ចអភិវឌ្ឍន៏ |
| **៣. វិសាលភាពគ្របដណ្ដប់**<br>☒ ប្រទេស ☐ អនុតំបន់ ☐ អន្តរតំបន់<br>☐ កិច្ចអភិវឌ្ឍន៏គោលនយោបាយថ្នាក់ជាតិ |
| **៤. ផ្នែក/នាយកដ្ឋានទទួលបន្ទុក:** ផ្នែកសង្គម/នាយកដ្ឋានមេគង្គ |
| **៥. មន្ត្រី ADB ទទួលបន្ទុក:** X. Ye ប្រធានអ្នកឯកទេសគម្រោង |
| **៦. ពិពណ៌នាអំពីជំនួយ**<br>**ក. សារៈតា/ការផ្សារភ្ជាប់ទៅនឹងយុទ្ធសាស្ត្រប្រចាំប្រទេស/តំបន់:** កិច្ចអភិវឌ្ឍន៏ជនបទ និង ការផ្គត់ផ្គង់ទឹក និងអនាម័យ ត្រូវបានដាក់បញ្ចូលទាំងពីរនៅក្នុង CSP របស់ ADB សម្រាប់កម្ពុជា។ គេឃើញមានការប្រមូលផ្តុំភាពក្រីក្រច្រើន នៅតំបន់ជនបទ ហើយកង្វះលទ្ធភាពទទួលបាននូវទឹកស្អាត និងបរិក្ខារអនាម័យ មានផលប៉ះពាល់អាក្រក់លើសុខភាព និង ស្ថានភាពរស់នៅនៃប្រជាជននៅជនបទ។ ក្នុងឆ្នាំ ២០០១ ADB បានផ្តល់ TA 3688-CAM: គម្រោងផ្គត់ផ្គង់ទឹក និងអនាម័យនៅជនបទ ដើម្បីជួយរាជរដ្ឋាភិបាលក្នុងការរៀបចំគម្រោងវិនិយោគមួយ ដែលសមស្របសម្រាប់ការផ្តល់ហិរញ្ញប្បទានរបស់ ADB។ ដើម្បីជួយរាជរដ្ឋាភិបាលក្នុងការបង្កើតបរិស្ថានច្បាប់ និងគោលនយោបាយឱ្យបានសមស្រប TA នេះបានជួយរាជរដ្ឋាភិបាលក្នុងការរៀបចំគោលនយោបាយផ្គត់ផ្គង់ទឹកនិងអនាម័យនៅជនបទ និង ផែនការវិនិយោគវិស័យផ្គត់ផ្គង់ទឹក និង អនាម័យនៅជនបទ។<br>**ខ. គោលដៅ និង គោលបំណង:** គម្រោង មានគោលបំណងរួមចំណែកដល់គោលដៅកាត់បន្ថយភាពក្រីក្រ របស់រាជរដ្ឋាភិបាល ដោយផ្តល់មូលនិធិវិនិយោគសម្រាប់កិច្ចអភិវឌ្ឍន៏ការផ្គត់ផ្គង់ទឹក និងបរិក្ខារអនាម័យនៅជនបទនៅក្នុងខេត្តចំនួនបីគឺ ពោធិ៍សាត់ កំពង់ធំ និងកំពត។ គម្រោងនេះនឹងរួមចំណែកដល់សមធមិយេនឌ័រ និងការផ្តល់អំណាច ដោយហេតុថា ពេលវេលាដែលត្រូវចំណាយសម្រាប់ការរកទឹកនឹងត្រូវបានកាត់បន្ថយ ហើយដោយហេតុនេះ ស្ត្រីនឹងមានពេលវេលាសម្រាប់ធ្វើសកម្មភាពរកប្រាក់ចំណូលផ្សេងៗនៅទីណាដែលមានសកម្មភាពទាំងនេះ។ គម្រោងក៏នឹងពង្រឹងផងដែរនូវសមត្ថភាពស្ថាប័ននៃស្ថាប័នសំខាន់ៗតាមខេត្ត ដើម្បីធានាថាស្ថាប័នទាំងនេះឆ្លើយតបទៅនឹងតម្រូវការ និង ប្រកបដោយចីរភាព។ |

គ. **សមាសភាគ និង សមិទ្ធិផលៈ** សមាសភាគគន្លឹះដែលត្រូវបានគ្រោង នឹងរួមមានៈ (១) កម្មវិធីអនាម័យ និងសុខភាពសហគមន៍មួយ (២) ប្រព័ន្ធនិងបរិក្ខារផ្គត់ផ្គង់ទឹក (៣) បរិក្ខារអនាម័យ (៤) ការបណ្តុះបណ្តាល និង (៥) គម្រោងការ និង ការកសាងសមត្ថភាព។

ឃ. **លទ្ធផលរំពឹងទុក និង អាចសម្រេចបានៈ** (១) ការយល់ដឹងកាន់តែខ្ពស់របស់សហគមន៍អំពីទំនាក់ទំនងរវាងទឹកស្អាត អនាម័យ និងសុខភាព ហើយនិងសមានចិត្តកាន់តែច្រើនឡើងរបស់សហគមន៍ក្នុងការចូលរួមវិភាគទានដល់វិនិយោគទុន និង បង់ប្រាក់សម្រាប់ប្រតិបត្តិការ និងការថែទាំ (O&M) (២) ប្រព័ន្ធផ្គត់ផ្គង់ទឹកដែលមានការរៀបចំដំណើរការប្រតិបត្តិការ និង ការថែទាំបានល្អ ហើយនិងបរិក្ខារអនាម័យដែលមានលក្ខណៈល្អខាងបរិស្ថាន (៣) សុខភាពប្រសើរឡើងរបស់ប្រជាជននៅក្នុងតំបន់អនុវត្តគម្រោង (៤) ការផ្តល់អំណាចដល់ស្ត្រីដោយធានាឱ្យបានថា ផល-ប្រយោជន៍របស់ពួកគេត្រូវបានការពារ និង ថាពួកគេបានចូលរួមនៅក្នុងគម្រោង ហើយនិង (៥) សមត្ថភាពប្រសើរឡើងនៃស្ថាប័នរាជរដ្ឋាភិបាលក្នុងការធ្វើផែនការការអនុវត្តន៍ និង ការត្រួតពិនិត្យកម្មវិធីផ្គត់ផ្គង់ទឹកនិងអនាម័យនៅជនបទនៅថ្នាក់ខេត្ត។

ង. **បញ្ហាឬការបារម្ភខាងសង្គម និងបរិស្ថានៈ** ការបារម្ភខាងសង្គម និងបរិស្ថានទាក់ទិននឹងកិច្ចអភិវឌ្ឍន៍ការផ្គត់ផ្គង់ទឹក និងអនាម័យនៅជនបទ និង O&M ត្រូវបានពិភាក្សាជាមួយភាគីពាក់ព័ន្ធ ក្នុងអំឡុងពេលសិក្សា TA ហើយនិងនៅក្នុងរយៈពេលអនុវត្តន៍គម្រោង។ ការយល់ដឹងនិងកិច្ចព្រមព្រៀងទាំងឡាយដែលគេសម្រេចបាន នឹងត្រូវបានដាក់បញ្ចូលទៅក្នុងការរៀបចំ និងការអនុវត្តន៍គម្រោង។

ច. **ផែនការសម្រាប់ផ្សព្វផ្សាយលទ្ធផល/សមិទ្ធផលៈ** មេរៀនសំខាន់ៗដែលគេបានរៀនសូត្រ និង ការអនុវត្តន៍ប្រកបដោយជោគជ័យ នឹងត្រូវបានផ្សព្វផ្សាយតាមរយៈសិក្ខាសាលា ហើយដែលលទ្ធផលនៃសិក្ខាសាលាទាំងនេះ នឹងត្រូវបានផ្សព្វផ្សាយជូនដល់ភាគីពាក់ព័ន្ធ។

៧. **ស្ថាប័នប្រតិបត្តិ/អនុវត្តដែលត្រូវបានស្នើឡើងៈ** ក្រសួងអភិវឌ្ឍន៍ជនបទ / មន្ទីរអភិវឌ្ឍន៍ជនបទខេត្ត-ក្រុង។

៨. **ប្រភេទ/កម្រិតនៃការចូលរួមរបស់រដ្ឋាភិបាល/អ្នកទទួលផលប្រយោជន៍នៅក្នុងការកំណត់ ឬការចាប់បដិសន្ធិជំនួយៈ**

ក្នុងអំឡុងពេលនៃការរៀបចំគម្រោងផ្គត់ផ្គង់ទឹក និងអនាម័យនៅជនបទ គេឃើញមានការពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធយ៉ាងច្រើន ជាមួយរដ្ឋាភិបាលថ្នាក់កណ្តាល និងថ្នាក់ខេត្ត NGOs និង សហគមន៍។ ដំណើរការនេះ នឹងបន្តទៅទៀតនៅក្នុងការជ្រើសរើសអនុគម្រោង និង ដំណើរការវាយតម្លៃ។

**៩. កាលវិភាគសម្រាប់ការរៀបចំគម្រោងជំនួយ ការពិនិត្យ និងការអនុវត្តនី:**

ក. ឆ្នាំដែលត្រូវបានដាក់បញ្ចូលក្នុង CSP, CSP ដែលបានធ្វើបច្ចុប្បន្នភាព, RCSP, RCSP ដែលបានធ្វើបច្ចុប្បន្នភាព ឬ ផែនការការងារអន្តរតំបន់: ឆ្នាំ ២០០២-២០០៤

ខ. កាលបរិច្ឆេទរំពឹងទុកនៃការដាក់សំណើសុំការឯកភាព

កម្ចីឥណទាន: ២០០៥

មិនមែនជាកម្ចីឥណទាន (សំរាប់ការត្រៀមរៀបចំគម្រោង): ២០០៥

គ. អំឡុងពេលនិងរយៈពេលនៃជំនួយ

កម្ចីឥណទាន: ២០០៥-២០១១

មិនមែនកម្ចីឥណទាន: ២០០៥

**១០. ផែនការហិរញ្ញប្បទាន**

ក. សម្រាប់ការផ្តល់កម្ចីឥណទាន

☐ ធនធានទុនធម្មតា:

☒ មូលនិធិអភិវឌ្ឍន៍អាស៊ី: ១៨ លានដុល្លារ ។

☐ ផ្សេងទៀត:

| **ប្រភព** | **ចំនួន (លានដុល្លារ)** |
|---|---|
| ហិរញ្ញប្បទាន ADB | ១៨,0 |
| ហិរញ្ញប្បទានរដ្ឋាភិបាល | ៤,៥ |
| ហិរញ្ញប្បទានផ្សេងទៀត | |
| **ចំណាយសរុប** | **២២,៥** |

ប្រភព: ការប៉ាន់ស្មានរបស់ ADB ។

ខ. សម្រាប់គំរោងមិនមែនជាកម្ចីឥណទាន

☐ មិនចាំបាច់មានធនធានទេ ក្រៅតែពីបុគ្គលិក ADB

☐ ថវិការដ្ឋបាលរបស់ ADB:

☒ មូលនិធិជំនួយបច្ចេកទេស

☐ ផ្សេងទៀត:

| ប្រភព | ចំនួន (លានដុល្លារ) |
| --- | --- |
| ហិរញ្ញប្បទាន ADB | ១៥0.000 |
| ហិរញ្ញប្បទានរដ្ឋាភិបាល | |
| ហិរញ្ញប្បទានផ្សេងទៀត | |
| **ចំណាយសរុប** | **១៥0.000** |

ប្រភព: ការប៉ាន់ស្មានរបស់ ADB ។

ADB = ធនាគារអភិវឌ្ឍន៍អាស៊ី CSP = យុទ្ធសាស្ត្រនិងកម្មវិធីប្រចាំប្រទេស RCSP = យុទ្ធសាស្ត្រនិងកម្មវិធីសហប្រតិបត្តិការប្រចាំតំបន់ TA = ជំនួយបច្ចេកទេស ។

## តារាង ក៤.២: កម្មវិធីវិស័យហិរញ្ញវត្ថុទី ១ ( អនុកម្មវិធីទី ៣)
## ឯកសារគោលគំនិត

**កាលបរិច្ឆេទ:** ថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០០៤

**១. ប្រភេទ/ទម្រង់នៃជំនួយ**

- ☒ ប្រភេទកម្ចីឥណទាន
  - ☐ ឥណទានគម្រោង
  - ☒ ឥណទានកម្មវិធីកំណែទម្រង់
  - ☐ ឥណទានវិស័យ
  - ☐ ឥណទានកម្មវិធីអភិវឌ្ឍន៍វិស័យ
  - ☐ ផ្សេងទៀត:
- ☐ ប្រភេទមិនមែនជាកម្ចីឥណទាន
  - ☐ សំរាប់ត្រៀមរៀបចំគម្រោង
  - ☐ ក្រៅពីសំរាប់ត្រៀមរៀបចំគម្រោង
    - ☐ ការងារផ្នែកសេដ្ឋកិច្ច ប្រធានបទ និង វិស័យ
    - ☐ កិច្ចអភិវឌ្ឍន៍ស្ថាប័ន
    - ☐ ផ្សេងទៀត:

**២. មុខព្រួញជំនួយ**

ក. ប្រសិនបើជំនួយផ្តោតលើវិស័យឬអនុវិស័យជាក់លាក់មួយ ចូរកំណត់

វិស័យ: វិស័យហិរញ្ញវត្ថុ

អនុវិស័យ:

ខ. សម្រាប់ការត្រៀមរៀបចំគម្រោងនិងការផ្តល់ឥណទាន ចំណាត់ថ្នាក់

- ☐ អន្តរាគមន៍មានមុខព្រួញ
- ☒ អន្តរាគមន៍ទូទៅ

គ. វិស័យប្រធានបទសំខាន់ៗ

ប្រធានបទ

☒ កំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព ☐ ចីរភាពបរិស្ថាន
☐ កិច្ចអភិវឌ្ឍន៍សង្គមរួម ☐ កិច្ចសហប្រតិបត្តិការតំបន់
☐ អភិបាលកិច្ច ☒ កិច្ចអភិវឌ្ឍន៍វិស័យឯកជន
☐ យេនឌ័រនិងកិច្ចអភិវឌ្ឍន៍

៣. វិសាលភាពគ្របដណ្តប់

☒ ប្រទេស ☐ អនុតំបន់ ☐ អន្តរតំបន់
☐ កិច្ចអភិវឌ្ឍន៍គោលនយោបាយថ្នាក់ជាតិ

៤. **ផ្នែក/នាយកដ្ឋានទទួលបន្ទុក:** ផ្នែកអភិបាលកិច្ច ហិរញ្ញវត្ថុ និង ពាណិជ្ជកម្ម/នាយកដ្ឋានមេគង្គ

៥. **មន្ត្រី ADB ទទួលបន្ទុក:** S. Tukuafu អ្នកឯកទេសហិរញ្ញវត្ថុ

៦. **ពិពណ៌នាអំពីជំនួយ**

ក. **សារៈតា/ការផ្សារភ្ជាប់ទៅនឹងយុទ្ធសាស្ត្រប្រចាំប្រទេស/តំបន់:** សេដ្ឋកិច្ចនៃប្រទេសកម្ពុជា បង្ហាញអន្តរការិយកម្មហិរញ្ញវត្ថុនៅមានកម្រិត ទំនុកចិត្តសាធារណៈលើធនាគារក៏ទាប និង គ្រឹះស្ថានហិរញ្ញវត្ថុមិនមែនធនាគារមួយចំនួននៅក្មេងខ្ចី។ ប្រព័ន្ធហិរញ្ញវត្ថុពុំទាន់អភិវឌ្ឍន៍ពេញលេញ គឺជាឧបសគ្គគន្លឹះចំពោះកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាពនិងដែលមានមូលដ្ឋានធំទូលាយ ហើយក៏ជាហេតុរាំងដល់គោលដៅអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមកិច្ចចំបងរបស់រាជរដ្ឋាភិបាលក្នុងការកាត់បន្ថយភាពក្រីក្រ។ ដូចគ្នានិងប្រព័ន្ធពាណិជ្ជកម្មកំពុងអភិវឌ្ឍដ៏ក្មេងខ្ចីដទៃទៀតដែរ វិស័យហិរញ្ញវត្ថុត្រូវបានរារាំងដោយ (១) ហានិភ័យខ្ពស់ពាក់ព័ន្ធនឹងធនាគារទន់ខ្សោយ និង ភាពមិនប្រាកដប្រជានៃការដាក់ឱ្យអនុវត្តកិច្ចសន្យានិងទ្រព្យធានា (២) ចំណាយលើព័ត៌មានខ្ពស់ដែលបណ្តាលមកពីកង្វះប្រព័ន្ធគណនេយ្យ ស្តង់ដារគណនេយ្យនិងសវនកម្មសមស្រប និង ហេដ្ឋារចនាសម្ព័ន្ធព័ត៌មានដទៃទៀត (៣) ចំណាយប្រតិបត្តិការខ្ពស់ដោយសារភាពទន់ខ្សោយនៅក្នុងប្រព័ន្ធទូទាត់ ការគ្រប់គ្រងសាច់ប្រាក់ងាយស្រួល និង ផ្នែកដទៃទៀតនៃហេដ្ឋារចនាសម្ព័ន្ធទីផ្សារ (៤) គ្រឹះស្ថានហិរញ្ញវត្ថុរដ្ឋគ្មានប្រសិទ្ធិភាព និង (៥) ប្រព័ន្ធនិងសមត្ថភាពត្រួតពិនិត្យទន់ខ្សោយ។

រាជរដ្ឋាភិបាលបានអភិវឌ្ឍយុទ្ធសាស្ត្រវិស័យរបស់ខ្លួន ដោយរៀបចំចក្ខុវិស័យផែនការវិស័យអភិវឌ្ឍន៍ហិរញ្ញវត្ថុសម្រាប់ឆ្នាំ ២០០១-២០១០ ដោយមានការជួយគាំទ្រពី ADB។ គម្រោងកាត់បន្ថយភាពក្រីក្រនិងកំណើនរបស់ IMF (PRGF) បានចាប់ផ្តើមក្នុងឆ្នាំ ១៩៩៩ បានពង្រឹងការត្រួតពិនិត្យធនាគារ និង បានរៀបចំរចនាសម្ព័ន្ធឧស្សាហកម្មធនាគារឡើងវិញ។ ឥណទានកម្មវិធី វិស័យហិរញ្ញវត្ថុ (FSPL I) បានបំពេញបន្ថែមលើកម្មវិធីរបស់ IMF ស្តីពីការត្រួតពិនិត្យ និងបានផ្តល់ផងដែរនូវជំនួយដល់វិស័យធានារ៉ាប់រង ទីផ្សាររូបិយវត្ថុ និង ហេដ្ឋារចនាសម្ព័ន្ធហិរញ្ញវត្ថុ។ FSPL I

ដែលផ្អែកលើចង្កោមឥណទាននៃអនុកម្មវិធីចំនួនបី ត្រូវបានអនុម័តក្នុងខែ វិច្ឆិកា ឆ្នាំ ២០០១ រួមជាមួយនិងអនុកម្មវិធីទី ១ ដែលមានទឹកប្រាក់ចំនួន ១០ លានដុល្លារ។ ក្រោយពេលបញ្ចប់ប្រកបដោយជោគជ័យនូវអនុកម្មវិធីទី ១ ADB បានអនុម័តអនុកម្មវិធីទី ២ នៅក្នុងខែ វិច្ឆិកា ឆ្នាំ ២០០២។ ការអនុវត្តន៍សកម្មភាពទាំងឡាយក្រោមអនុកម្មវិធីទី ២ គឺស្ថិតក្នុងតំណាក់កាលវិវឌ្ឍន៍ បោះជំហានទៅមុខជិតដល់ទីបញ្ចប់ហើយ។

**ការផ្សារភ្ជាប់ទៅនឹងយុទ្ធសាស្ត្រប្រចាំប្រទេស:** កិច្ចអភិវឌ្ឍន៍វិស័យឯកជនគឺជាគ្រឹះមួយនៃសសរគ្រឹះទាំងឡាយនៃប្រតិបត្តិការរបស់ ADB នៅក្នុងប្រទេសកម្ពុជា។ កិច្ចអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុគឺជាគោលដៅអាទិភាពមួយ ហើយវិស័យនេះ គឺជាវិស័យមួយដែលនៅក្នុងនោះ ADB បានដើរតួនាទីនាំមុខគេរហូតមកទល់បច្ចុប្បន្ននេះ។

ខ. **គោលដៅ និង គោលបំណង:** ផ្អែកលើសមិទ្ធិផលសម្រេចបានក្រោមអនុកម្មវិធីទី ១ និង ទី ២ នៃ FSPL I អនុកម្មវិធីទី ៣ នឹងពង្រឹងការអនុវត្តន៍ផែនការវិស័យហិរញ្ញវត្ថុដែលត្រូវបានធ្វើបច្ចុប្បន្នកម្មនិងដែលត្រូវបានអនុម័ត និង ផ្តួចផ្តើមការអនុវត្តន៍វិស័យជាក់លាក់ទាំងឡាយនៃតំណាក់កាលបន្ទាប់នៃកំណែទម្រង់វិស័យហិរញ្ញវត្ថុនៅកម្ពុជា។ គោលដៅ គឺសំដៅគាំទ្រកិច្ចអភិវឌ្ឍន៍ប្រព័ន្ធហិរញ្ញវត្ថុដ៏រឹងមាំ និងប្រកបដោយប្រសិទ្ធិភាពមួយដែលនឹងលើកកំពស់ប្រសិទ្ធិភាពនៅក្នុងការគៀងគរធនធាន និង រួមចំណែកដល់កំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព។

គ. **សមាសភាគ និង សមិទ្ធិផល:** ផ្អែកលើសមិទ្ធិផលសម្រេចបានក្រោមអនុកម្មវិធីទី ១ និង ទី ២ និង ឈរលើផែនការវិស័យហិរញ្ញវត្ថុដែលត្រូវបានធ្វើបច្ចុប្បន្នកម្មនិងដែលត្រូវបានអនុម័ត សមាសភាគចំបងទាំងឡាយនៃអនុកម្មវិធីទី ៣ រួមមាន ទី(១) ពង្រឹងតួនាទីត្រួតពិនិត្យប្រុងប្រយ័ត្នរបស់ធនាគារជាតិនៃកម្ពុជា (NBC) និង ការពង្រីកការកសាងសមត្ថភាពត្រួតពិនិត្យទៅក្នុងវិស័យថ្មីៗ (ដែលរួមមាន (ក) ការគាំទ្របន្ថែមចំពោះការអនុវត្តន៍ប្លង់គណនី និង ស្តង់ដារផ្តល់ព័ត៌មាន (ខ) ការណែនាំបុគ្គលិក NBC នៅក្នុងការធ្វើអធិការកិច្ចនៅនឹងកន្លែងឱ្យបានពេញលេញ (គ) ការពង្រីកការកសាងសមត្ថភាពត្រួតពិនិត្យទៅក្នុងវិស័យមីក្រូហិរញ្ញវត្ថុ ភតិសន្យា និង គ្រឹះស្ថានហិរញ្ញវត្ថុដទៃទៀត) ទី(២) ពង្រឹងការអនុវត្តន៍ក្របខ័ណ្ឌច្បាប់និងបទប្បញ្ញត្តិដែលមានស្រាប់ និង គាំទ្រកិច្ចអភិវឌ្ឍន៍ច្បាប់និងបទប្បញ្ញត្តិរបស់រាជរដ្ឋាភិបាល និង ប្រព័ន្ធតុលាការមួយដែលសមស្របសម្រាប់វិស័យនេះ ទី(៣) គាំទ្រដកវិនិយោគរបស់រដ្ឋាភិបាលចេញពីអាជីវកម្មធានារ៉ាប់រង និង ពង្រឹងក្របខ័ណ្ឌបទប្បញ្ញត្តិសម្រាប់ប្រតិបត្តិការងារធានារ៉ាប់រងដ៏រឹងមាំ (៤) ពង្រឹងទីផ្សារអន្តរធនាគារនិងទីផ្សាររូបិយវត្ថុ និង (៥) អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធទីផ្សារហិរញ្ញវត្ថុ រួមទាំងកិច្ចអភិវឌ្ឍន៍បន្ថែមទៀតនូវវិជ្ជាជីវៈគណនេយ្យនិងសវនកម្ម តុលាការពាណិជ្ជកម្មនៅក្នុងប្រព័ន្ធតុលាការ ការផ្លាស់ប្តូរព័ត៌មានឥណទាន។ល។

ឃ. **លទ្ធផលរំពឹងទុក និង អាចសម្រេចបាន:** ក្រោយពេលបញ្ចប់អនុកម្មវិធីទី ៣ គេរំពឹងថា ទី(១) កិច្ចអភិវឌ្ឍន៍វិស័យធនាគារ: ការត្រួតពិនិត្យប្រុងប្រយ័ត្ននៃធនាគារជាតិនៃកម្ពុជានឹងត្រូវបានពង្រឹង ជំនាញរបស់បុគ្គលិកធនាគារនឹងត្រូវ

បានលើកកំពស់តាមរយៈការបណ្តុះបណ្តាលដែលត្រូវបានផ្តល់ជូនដោយវិទ្យាស្ថានធនាគារឯកជន ហើយទំនុកចិត្តលើវិស័យធនាគារនឹងត្រូវបានកែលំអយ៉ាងច្រើន ទី(២) កិច្ចអភិវឌ្ឍន៍វិស័យធានារ៉ាប់រង: បទប្បញ្ញត្តិនឹងត្រូវបានពង្រឹងសមត្ថភាពនៃអ្នកគ្រប់គ្រងការងារធានារ៉ាប់រងនឹងត្រូវបានលើកកំពស់ ហើយក្រុមហ៊ុនធានារ៉ាប់រងរដ្ឋនឹងត្រូវបានរៀបចំរចនាសម្ព័ន្ធឡើងវិញ និង ត្រូវបានដកវិនិយោគចេញ ទី(៣) កិច្ចអភិវឌ្ឍន៍ទីផ្សារហិរញ្ញវត្ថុ: ច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាននិងប្រតិបត្តិការទូទាត់ នឹងត្រូវបានអនុម័តនិងអនុវត្ត ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្មត្រូវបានអនុម័តនិងអនុវត្ត ហើយសេចក្តីព្រាងច្បាប់មូលប័ត្រនិងទីផ្សារហ៊ុននឹងត្រូវបានដាក់ជូនរដ្ឋសភាជាតិ និង ទី(៤) កិច្ចអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ: ច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានានឹងត្រូវបានអនុម័ត ហើយប្រព័ន្ធចុះបញ្ជីអេឡិចត្រូនិកជាសាធារណៈសម្រាប់ប្រតិបត្តិការដែលមានកិច្ចធានានឹងត្រូវបានបង្កើតឡើង វិទ្យាស្ថានគណនេយ្យនិងសវនកម្មនឹងត្រូវបានពង្រឹង ស្តង់ដារដែលត្រូវបានឯកភាពនឹងត្រូវបានអនុម័តយ៉ាងទូលាយ គេនឹងឃើញមានការកែលំអបន្ថែមទៀតចំពោះប្រព័ន្ធតុលាការ ដើម្បីជួយដល់ការដាក់ឱ្យអនុវត្តកិច្ចសន្យា។

ង. **បញ្ហាឬការបារម្ភខាងសង្គមកិច្ចឬបរិស្ថាន:** ផលប៉ះពាល់សង្គមកិច្ចគឺមានលក្ខណៈវិជ្ជមាន ហើយបញ្ហាបរិស្ថានគឺមានតិចបំផុត។

ច. **ផែនការផ្សព្វផ្សាយលទ្ធផល/សមិទ្ធិផល:** ADB នឹងរក្សាការពិភាក្សាគោលនយោបាយដ៏សកម្មជាមួយភាគីពាក់ព័ន្ធវិស័យសាធារណៈនិងឯកជនទាំងអស់នៅក្នុងការរៀបចំកម្មវិធី និង ផ្សព្វផ្សាយលទ្ធផលនៃកម្មវិធី។

៧. **ស្ថាប័នប្រតិបត្តិ/អនុវត្តដែលត្រូវបានស្នើឡើង:** ធនាគារជាតិនៃកម្ពុជាគឺជាស្ថាប័នប្រតិបត្តិ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង ក្រសួងពាណិជ្ជកម្ម ជាស្ថាប័នអនុវត្ត។

៨. **ប្រភេទ/កម្រិតនៃការចូលរួមរបស់រដ្ឋាភិបាល/អ្នកទទួលផលប្រយោជន៍ក្នុងការផ្តើមគោលគំនិត និង កំណត់អំពីគម្រោងជំនួយ:** ការរៀបចំគម្រោងគឺផ្អែកលើផែនការវិស័យហិរញ្ញវត្ថុសម្រាប់ឆ្នាំ ២០០១-២០១០ ដែលត្រូវបានរៀបចំឡើងដោយមានការចូលរួមពីភាគីពាក់ព័ន្ធវិស័យសាធារណៈនិងឯកជនទាំងអស់។ រាជរដ្ឋាភិបាលបានអនុម័តផែនការនេះនៅក្នុងខែសីហា ឆ្នាំ ២០០១ និង មានគម្រោងធ្វើបច្ចុប្បន្នកម្មផែនការនេះ ដោយចាប់ផ្តើមនៅក្នុងត្រីមាសទីបួននៃឆ្នាំ ២០០៤។ ព័ត៌មានពិស្តារនៃអនុកម្មវិធីទី ៣ នឹងត្រូវបានកែលំអបន្ថែមទៀតក្រោយពីមានការវាយតម្លៃលើវឌ្ឍនភាពមកទល់បច្ចុប្បន្ននេះ និងការពិភាក្សាជាមួយស្ថាប័នរដ្ឋាភិបាល និង ភាគីពាក់ព័ន្ធវិស័យឯកជន។ ដោយហេតុនេះ គម្រោងការណ៍ចុងក្រោយនៃកម្មអនុវិធីនេះ នឹងឆ្លុះបញ្ចាំងការប្រែប្រួលនៅក្នុងបរិយាកាសសង្គម នយោបាយ និង សេដ្ឋកិច្ច នឹងផ្អែកលើវឌ្ឍនភាពដែលស្ថាប័ន រដ្ឋាភិបាល និង ភាគីពាក់ព័ន្ធវិស័យឯកជនសម្រេចបានក្រោមអនុកម្មវិធីមុនទាំងពីរ។

៩. **កាលវិភាគសម្រាប់ការរៀបចំគម្រោងជំនួយ ការពិនិត្យ និង ការអនុវត្តន៍:**

| |
|---|
| ក. ឆ្នាំដែលត្រូវបានដាក់បញ្ចូលក្នុង CSP, CSP ថ្មី, RCSP, RCSP ថ្មី ឬ ផែនការការងារអន្តរតំបន់: ឆ្នាំ ២០០៤<br><br>ខ. កាលបរិច្ឆេទរំពឹងទុកនៃការដាក់សំណើសុំការឯកភាព<br><br>កម្ចីឥណទាន: ២០០៥<br>មិនមែនជាកម្ចីឥណទាន (សំរាប់ការត្រៀមរៀបចំគម្រោង):<br>មិនមែនជាកម្ចីឥណទាន (ក្រៅពីការត្រៀមរៀបចំគម្រោង):<br><br>គ. អំឡុងពេលនិងរយៈពេលនៃជំនួយ<br><br>កម្ចីឥណទាន: ២០០៥-២០០៦<br>មិនមែនកម្ចីឥណទាន: |
| ១០. **ផែនការហិរញ្ញប្បទាន**<br><br>ក. សម្រាប់ការផ្តល់កម្ចីឥណទាន<br><br>☐ ធនធានទុនធម្មតា:<br>☒ មូលនិធិអភិវឌ្ឍន៍អាស៊ី: ១០ លានដុល្លារ<br>☐ ផ្សេងទៀត: |

ADB = ធនាគារអភិវឌ្ឍន៍អាស៊ី CSP = យុទ្ធសាស្ត្រនិងកម្មវិធីប្រចាំប្រទេស IMF = មូលនិធិរូបិយវត្ថុអន្តរជាតិ RCSP = យុទ្ធសាស្ត្រនិងកម្មវិធីសហប្រតិបត្តិការ ប្រចាំតំបន់ TA = ជំនួយបច្ចេកទេស។

## តារាង ក៤.៣: ជីវភាពប្រកបដោយចីរភាពនៅតំបន់បឹងទន្លេសាប

## ឯកសារគោលគំនិត

**កាលបរិច្ឆេទ:** ថ្ងៃទី ២ ខែ ធ្នូ ឆ្នាំ ២០០៤

| |
|---|
| ១. ប្រភេទ/ទម្រង់នៃជំនួយ<br>☒ ប្រភេទកម្ចីឥណទាន<br>☒ ឥណទានគម្រោង<br>☐ ឥណទានកម្មវិធីកំណែទម្រង់<br>☐ ឥណទានវិស័យ<br>☐ ឥណទានកម្មវិធីអភិវឌ្ឍន៍វិស័យ<br>☐ ផ្សេងទៀត:<br>☐ ប្រភេទមិនមែនជាកម្ចីឥណទាន<br>☐ សំរាប់ត្រៀមរៀបចំគម្រោង<br>☐ ក្រៅពីសំរាប់ត្រៀមរៀបចំគម្រោង<br>☐ ការងារផ្នែកសេដ្ឋកិច្ច ប្រធានបទ និង វិស័យ<br>☐ កិច្ចអភិវឌ្ឍន៍ស្ថាប័ន<br>☐ ផ្សេងទៀត: |
| ២. មុខព្រួញជំនួយ<br>ក. ប្រសិនបើជំនួយផ្តោតលើវិស័យឬអនុវិស័យជាក់លាក់មួយ ចូរកំណត់<br>វិស័យ: កសិកម្ម និង ធនធានធម្មជាតិ<br>អនុវិស័យ: នេសាទ<br>ខ. សម្រាប់ការត្រៀមរៀបចំគម្រោងនិងការផ្តល់ឥណទាន ចំណាត់ថ្នាក់<br>☒ អន្តរាគមន៍មានមុខព្រួញ<br>☐ អន្តរាគមន៍ទូទៅ<br>គ. វិស័យប្រធានបទសំខាន់ៗ<br>ប្រធានបទ |

☒ កំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព ☒ ចីរភាពបរិស្ថាន
☐ កិច្ចអភិវឌ្ឍន៍សង្គមរួម ☐ កិច្ចសហប្រតិបត្តិការតំបន់
☐ អភិបាលកិច្ច ☐ កិច្ចអភិវឌ្ឍន៍វិស័យឯកជន
☒ យេនឌ័រនិងកិច្ចអភិវឌ្ឍន៍

៣. វិសាលភាពគ្របដណ្តប់

☒ ប្រទេស ☐ អនុតំបន់ ☐ អន្តរតំបន់
☐ កិច្ចអភិវឌ្ឍន៍គោលនយោបាយថ្នាក់ជាតិ

៤. **ផ្នែក/នាយកដ្ឋានទទួលបន្ទុក:** ផ្នែកកសិកម្ម បរិស្ថាន និង ធនធានធម្មជាតិ/នាយកដ្ឋានមេគង្គ

៥. **មន្ត្រី ADB ទទួលបន្ទុក:** O. Serrat អ្នកសេដ្ឋកិច្ចគម្រោងជាន់ខ្ពស់ (ធនធានធម្មជាតិ)

៦. ពិពណ៌នាអំពីជំនួយ

ក. **សារ:តា/ការផ្សារភ្ជាប់ទៅនឹងយុទ្ធសាស្ត្រប្រចាំប្រទេស/តំបន់:** ការប្រយុទ្ធនឹងភាពក្រីក្រនៅកម្ពុជា មានន័យថាគឺជាការធ្វើការងារជាមួយប្រជាពលរដ្ឋក្រីក្រនៅជនបទ ជាដំបូងនៅទីណាដែលទ្រព្យជីវភាពកំពុងរងផលប៉ះពាល់ពីនិន្នាការមិនអំណោយផលទាំងឡាយ ដូចជា ការធ្វើនេសាទច្រើនពេក គ្រោះរាំងស្ងួត ការរីករាលដាលនៃសត្វល្អិតចង្រៃ ទឹកជំនន់ ឬ ការខូចខាតនៃហេដ្ឋារចនាសម្ព័ន្ធ។ និន្នាការបែបនេះគឺមើលឃើញច្បាស់នៅក្នុងតំបន់បឹងទន្លេសាបនៃប្រទេសកម្ពុជា។ ទោះបីជាមានធនធានធម្មជាតិសន្ធឹកសន្ធាប់នៃបឹងទន្លេសាបក្តី ក៏ភាពក្រីក្រមានលក្ខណៈពាសពេញដែរ។ សមាមាត្រនៃប្រជាជនដែលរស់នៅក្រោមបន្ទាត់ក្រីក្រផ្លូវការនៅក្នុងខេត្តទាំងប្រាំនៅជុំវិញបឹងទន្លេសាប គឺមានលក្ខណៈខ្ពស់បំផុតនៅក្នុងប្រទេស។ ភូមិចំនួនប្រមាណជា ៥០% មានគ្រួសារចំនួន ៤០-៦០% ដែលរស់នៅក្រោមបន្ទាត់ក្រីក្រ ជាមួយនឹងចំនួនច្រើនបំផុតដល់ទៅ ៨០% នៅក្នុងតំបន់ជនបទខ្លះៗនៃខេត្តសៀមរាប និង កំពង់ឆ្នាំង។ ស្ត្រីគឺមានលក្ខណៈងាយ-រងគ្រោះជាពិសេស។ លើសពីនេះទៀត ពួកគេមានលទ្ធភាពតិចជាងបុរសក្នុងការទទួលកម្មសិទ្ធិដីធ្លី និង សិទ្ធិលើទ្រព្យសម្បត្តិដទៃទៀត ឥណទាន ការងារមានប្រាក់កំរៃ ការអប់រំ និង សេវាកម្មសុខាភិបាល។ ពួកគេក៏មានឱកាសតិចជាងសម្រាប់កិច្ចអភិវឌ្ឍន៍ខ្លួនឯង ឬ ការចូលរួមក្នុងការធ្វើសេចក្តីសម្រេចចិត្តនៅសហគមន៍ដោយសារប្រពៃណីខ្មែរកំណត់តួនាទីអកម្មចំពោះស្ត្រី។ គេឃើញកាន់តែមានការបារម្ភអំពីការធ្វើអាជីវកម្មគ្មានចីរភាព លើធនធានធម្មជាតិនៃបឹងទន្លេសាប: ប្រទេសកម្ពុជា ប្រឈមមុខនឹងគ្រោះមហន្តរាយខាងបរិស្ថាន ប្រសិនបើប្រព័ន្ធអេកូឡូស៊ីដ៏ផុយស្រួយនៃបឹងទន្លេសាបត្រូវបានធ្វើឱ្យខូចខាតបន្ថែមទៀត។ ជាពិសេសនេសាទលើបឹងទន្លេសាបត្រូវបានកត់សំគាល់ដោយវិសមធម៌នៃការបែងចែកប្រតិបត្តិការមិនសុចរិត អំពើពុករលួយច្រើន ការខូចខាតបរិស្ថានបណ្តាលមកពីគម្រូធ្វើអាជីវកម្មគ្មានចីរភាព និងវិវាទដែលកាន់តែកើនឡើង។ ទន្ទឹមនឹងនេះ ព្រៃឈើលិចទឹកកំពុងត្រូវបានកាប់ដើម្បីការដាំដំណាំរកប្រាក់

ចំណូល។ លទ្ធភាពក្នុងការដោះស្រាយបញ្ហាទាំងអស់នេះ ត្រូវបានកាត់បន្ថយចុះនៅក្នុងសង្គមកម្ពុជានៅ គ្រប់កម្រិត ដោយសារសង្គ្រាមច្រើនឆ្នាំ។ លើសពីនេះទៀត ប្រជាជនផ្លាស់ទីលំនៅក្នុងស្រុក ជនភៀសខ្លួនធ្វើមាតុភូមិ-និវត្តន៍ អ្នកធ្វើចំណាកស្រុកផ្ទៃក្នុង និង យោធារំសាយជាច្រើន កំពុងកសាងឡើងវិញនូវជីវភាពរបស់ពួកគេនៅក្នុងសង្គម មួយដែលនៅតែមានលក្ខណៈតោកយ៉ាក (តំបន់ទិសពាយព្យនៃបឹងទន្លេសាប ដូចជាខេត្តសៀមរាប ទើបបានទទួល សន្តិភាពចាប់តាំងពីឆ្នាំ ១៩៩៨ មកតែប៉ុណ្ណោះ។)

ខ. **គោលដៅ និង គោលបំណង:** គោលដៅនៃគម្រោងនេះ គឺការគ្រប់គ្រង និងអភិរក្សប្រកបដោយចីរភាពនូវ ធនធានធម្មជាតិ និង ជីវៈចម្រុះនៅក្នុងអាងបឹងទន្លេសាប។ គោលបំណងនៃគម្រោង គឺការថែរក្សា និងកែលំអជីវភាព នៅក្នុងតំបន់លិចទឹកនៃបឹងទន្លេសាប។

គ. **សមាសភាគ និង សមិទ្ធិផល:** សមាសភាគ និង ទិន្នផលនៃគម្រោងនេះ កំពុងត្រូវបានរៀបចំក្រោម TA 4197–CAM: ជីវភាពប្រកបដោយចីរភាពនៅបឹងទន្លេសាប។ សមាសភាគ និង ទិន្នផលទាំងនេះនឹងទាក់ទិននឹងការគាំទ្រដោយផ្ទាល់ និង ប្រយោលចំពោះការគៀងគរជំនួយបន្ថែម។ នឹងមានការរាប់បញ្ចូលផងដែរនូការគ្រប់គ្រងធនធានធម្មជាតិផ្អែកលើ សហគមន៍ មូលនិធិអភិវឌ្ឍន៍ភូមិ ពិពិធកម្មជីវភាព កម្មវិធីអក្ខរកម្មក្រោយពេលឈប់រៀន និង ការអប់រំវិជ្ជាជីវៈ ដោយ បន្ថែមតម្លៃចំពោះផលិតផលត្រី និង ការគាំទ្រជាបន្តចំពោះច្បាប់ថ្មីស្តីពីនេសាទ និង ផែនការនេសាទទូទៅសម្រាប់ការ គ្រប់គ្រងនិងកិច្ចអភិវឌ្ឍន៍បឹងទន្លេសាប។

ឃ. **លទ្ធផលរំពឹងទុក និង អាចសម្រេចបាន:** លទ្ធផលរំពឹង និង សមិទ្ធិផលនៃគម្រោងនេះកំពុងត្រូវបានរៀបចំក្រោម TA 4197–CAM: ជីវភាពប្រកបដោយចីរភាពនៅបឹងទន្លេសាប។

ង. **បញ្ហាឬការបារម្ភខាងសង្គមកិច្ចឬបរិស្ថាន:** បឹងទន្លេសាប គឺជាតំបន់សើមនៅឆ្ងាយពីសមុទ្រដ៏សំខាន់បំផុតនៅក្នុង អាស៊ីអគ្នេយ៍។ បឹងទន្លេសាបទ្រទ្រង់ប្រជាជនយ៉ាងច្រើន តាមរយៈផលិតភាពនេសាទដ៏ធំធេងនិងការផ្គត់ផ្គង់ទឹករបស់វា និង ផ្តល់នូវជម្រកចុងក្រោយសម្រាប់ជីវៈចម្រុះខ្លះដែលមានលក្ខណៈសំខាន់បំផុតជាសកលរបស់ទ្វីបអាស៊ី។ នេសាទនៃ បឹងនេះផ្តល់ការទទួលទានប្រូតេអ៊ីនចំនួន ៤០-៧០% នៃប្រជាជនកម្ពុជា ដែលក្នុងនោះ ប្រជាជនចំនួន ៥០% ពឹងផ្អែក លើធនធានបឹងទន្លេសាបដោយផ្ទាល់ឬដោយប្រយោល ខណៈដែលប្រជាជនប្រហែល ១ លាននាក់រស់នៅក្នុងសហគមន៍ ដែលអាស្រ័យលើនេសាទ។ ប៉ុន្តែ ចំនួនមនុស្សនិងសំពាធអភិវឌ្ឍន៍កំពុងតែកើនឡើង ហើយ ទោះបីជាបឹងនេះមាន ធនធានធម្មជាតិច្រើនក្តី ក៏សូចនាករនៃភាពក្រីក្រភាគច្រើននៅក្នុងតំបន់បឹងទន្លេសាប គឺមានលក្ខណៈអវិជ្ជមានជាង សូចនាករទាំងឡាយដែលពាក់ព័ន្ធនឹងប្រជាជនក្នុងប្រទេសទាំងមូល ឬ តំបន់ជនបទដទៃទៀតនៅក្នុងប្រទេសកម្ពុជា។ ភូមិចំនួនពាក់កណ្តាលនៅក្នុងតំបន់បឹងទន្លេសាប មានគ្រួសារចំនួន ៤០-៦០% នៅក្រោមបន្ទាត់ក្រីក្រផ្លូវការ ដោយមាន ចំនួនច្រើនបំផុតដល់ ៨០% នៅក្នុងតំបន់ខ្លះ។ ស្ត្រីទទួលបន្ទុកធ្ងន់ធ្ងរដោយសារការស្លាប់របស់បុរសក្នុងអំឡុងពេល

សង្គ្រាមរ៉ាំរ៉ៃ និង របបប្រល័យពូជសាសន៍។ គេក៏ឃើញមានផងដែរនូវទិដ្ឋភាពជាតិពន្ធដ៏រសើប ដោយសារជនជាតិភាគតិចវៀតណាម និង ខ្មែរអ៊ីស្លាម រស់នៅក្នុងតំបន់បឹងទន្លេសាប។ សំពាធទាំងនេះកំពុងតែនាំឱ្យមានទំនាក់ទំនងរវាងបរិស្ថាននិងភាពក្រីក្រកាន់តែមានលក្ខណៈតឹងតែងឡើង។

ច. **ផែនការសម្រាប់ផ្សព្វផ្សាយលទ្ធផល/ស្នាដៃៈ** សមិទ្ធិផលនៃគម្រោងនេះនឹងត្រូវបានផ្សព្វផ្សាយ តាមរយៈបណ្តាញព័ត៌មាននៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ និង ក្រសួងអភិវឌ្ឍន៍ជនបទ។ នៅក្នុង ADB សមិទ្ធិផលទាំងនេះនឹងត្រូវបានចែកចាយនៅក្នុងកូនសៀវភៅព័ត៌មានប្រចាំត្រីមាសស្តីពីគំនិតផ្តួចផ្តើមបឹងទន្លេសាប និង នៅក្នុងគេហទំព័រ (website) នៃគម្រោងគ្រប់គ្រងបរិស្ថាននៅបឹងទន្លេសាប។

៧. **ស្ថាប័នប្រតិបត្តិ/អនុវត្តដែលត្រូវបានស្នើឡើងៈ** ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ និង ក្រសួងអភិវឌ្ឍន៍ជនបទ។

៨. **ប្រភេទ/កម្រិតនៃការចូលរួមរបស់រដ្ឋាភិបាល/អ្នកទទួលផលប្រយោជន៍នៅក្នុងការកំណត់ ឬការចាប់បដិសន្ធិជំនួយៈ**

គម្រោងនេះកំពុងត្រូវបានរៀបចំឡើងក្រោម TA 4197-CAM: ជីវភាពប្រកបដោយចីរភាពនៅបឹងទន្លេសាប។ TA នេះកំពុងត្រូវបានអនុវត្តនៅក្នុងពីរតំណាក់កាល។ ដោយប្រើអភិក្រមជីវភាព គម្រោងនេះបានតម្រូវឱ្យមានទស្សនៈកាន់តែទូលាយនិងកាន់តែមានការយល់ដឹងល្អអំពីកាលានុវត្តភាព ឧបសគ្គ គោលដៅ និង ទំនាក់ទំនងទាំងឡាយដែលបង្ហាញពីជីវិតរបស់ប្រជាជននៅក្នុងតំបន់លិចទឹកនៃខេត្តទាំងប្រាំដែលនៅជាប់នឹងបឹងទន្លេសាប។ តំណាក់កាលទី ១ រួមមានការវាយតម្លៃជនបទយ៉ាងច្រើន។

៩. **កាលវិភាគសម្រាប់សំរាប់ការរៀបចំគម្រោងជំនួយ ការពិនិត្យ និង ការអនុវត្តន៍ៈ**

ក. ឆ្នាំដែលត្រូវបានដាក់បញ្ចូលក្នុង CSP, CSP ថ្មី, RCSP, RCSP ថ្មី ឬ ផែនការការងារអន្តរតំបន់ៈ ឆ្នាំ ២០០២

ខ. កាលបរិច្ឆេទរំពឹងនៃការដាក់សំណើសុំការឯកភាព

កម្ចីឥណទានៈ ២០០៥
មិនមែនជាកម្ចីឥណទាន (សំរាប់ការត្រៀមរៀបចំគម្រោង):

មិនមែនជាកម្ចីឥណទាន (ក្រៅពីការត្រៀមរៀបចំគម្រោង):

គ. អំឡុងពេលនិងរយៈពេលនៃជំនួយ

កម្ចីឥណទានៈ ២០០៥-២០០៩
មិនមែនជាកម្ចីឥណទាន :

**១០. ផែនការហិរញ្ញប្បទាន**

ក. សម្រាប់ការផ្តល់កម្ចីឥណទាន

- ☐ ធនធានទុនធម្មតា:
- ☒ មូលនិធិអភិវឌ្ឍន៍អាស៊ី: ១៥ លានដុល្លារ ។
- ☐ ផ្សេងទៀត:

ADB = ធនាគារអភិវឌ្ឍន៍អាស៊ី CSP = យុទ្ធសាស្ត្រនិងកម្មវិធីប្រចាំប្រទេស RCSP = យុទ្ធសាស្ត្រនិងកម្មវិធីសហប្រតិបត្តិការប្រចាំតំបន់ TA = ជំនួយបច្ចេកទេស ។

## តារាង ក៤.៤: អនុតំបន់ទន្លេមេគង្គ: ការទប់ស្កាត់ជម្ងឺឆ្លងនៅតំបន់ព្រំដែន

## ឯកសារគោលគំនិត

**កាលបរិច្ឆេទ:** ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០០៤

**១. ប្រភេទ/ទម្រង់នៃជំនួយ**

☒ ប្រភេទកម្ចីឥណទាន

- ☐ ឥណទានគម្រោង
- ☐ ឥណទានកម្មវិធីកំណែទម្រង់
- ☐ ឥណទានវិស័យ
- ☐ ឥណទានកម្មវិធីអភិវឌ្ឍន៏វិស័យ
- ☒ ផ្សេងទៀត:

☒ ប្រភេទមិនមែនជាកម្ចីឥណទាន

- ☒ សំរាប់ត្រៀមរៀបចំគម្រោង
- ☐ ក្រៅពីសំរាប់ត្រៀមរៀបចំគម្រោង
  - ☐ ការងារផ្នែកសេដ្ឋកិច្ច ប្រធានបទ និង វិស័យ
  - ☐ កិច្ចអភិវឌ្ឍន៍ស្ថាប័ន
  - ☐ ផ្សេងទៀត:

**២. មុខព្រួញជំនួយ**

ក. ប្រសិនបើគំរោងផ្តោតលើវិស័យឬអនុវិស័យជាក់លាក់មួយ ចូរបញ្ជាក់

វិស័យ: សុខាភិបាល

អនុវិស័យ: ប្រព័ន្ធ

ខ. សម្រាប់ការត្រៀមរៀបចំគម្រោងនិងការផ្តល់ឥណទាន ចំណាត់ថ្នាក់

- ☒ អន្តរាគមន៏មានមុខសញ្ញា
- ☐ អន្តរាគមន៏ទូទៅ

គ. វិស័យប្រធានបទសំខាន់ៗ

ប្រធានបទ

☐ កំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព ☐ ចីរភាពបរិស្ថាន

☒ កិច្ចអភិវឌ្ឍន៍សង្គមរួម ☒ កិច្ចសហប្រតិបត្តិការតំបន់

☐ អភិបាលកិច្ច ☐ កិច្ចអភិវឌ្ឍន៍វិស័យឯកជន

☒ យេនឌ័រនិងកិច្ចអភិវឌ្ឍន៍

**៣. វិសាលភាពគ្របដណ្តប់**

☐ ប្រទេស ☒ អនុតំបន់ ☐ អន្តរតំបន់

☐ កិច្ចអភិវឌ្ឍន៍គោលនយោបាយថ្នាក់ជាតិ

**៤. ផ្នែក/នាយកដ្ឋានទទួលបន្ទុកៈ** វិស័យសង្គម/នាយកដ្ឋានមេគង្គ

**៥. មន្ត្រី ADB ទទួលបន្ទុកៈ** V. de Wit អ្នកឯកទេសសុខាភិបាលជាន់ខ្ពស់

**៦. ពិពណ៌នាអំពីជំនួយ**

ក. **សារតា/ការផ្សារភ្ជាប់ទៅនឹងយុទ្ធសាស្ត្រប្រចាំប្រទេស/តំបន់ៈ** ប្រទេសកម្ពុជា សាធារណៈរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ និង ប្រទេសវៀតណាម ប្តេជ្ញាចិត្តសម្រេចឱ្យបាននូវគោលដៅអភិវឌ្ឍន៍ប្រចាំសហស្សវត្សរ៍ (MDGs) មុនដំណាច់ឆ្នាំ ២០១៥។ គោលដៅមួយនៃ MDGs តម្រូវឱ្យមានការរាំងខ្ទប់នៃជម្ងឺឆ្លង រួមទាំងមេរោគហ៊ីវ/ ជម្ងឺអេដស៍។ ការទប់ស្កាត់ជម្ងឺឆ្លងកម្រិតខ្ពស់គឺមានសារៈសំខាន់ក្រៃលែងដើម្បីសម្រេចបាននូវ MDGs ដើម្បីកាត់បន្ថយការស្លាប់របស់កុមារនិងម្តាយ កង្វះអាហារូបត្ថម្ភ និង ភាពក្រីក្រ។ ប្រជាជនក្រីក្រទទួលរងគ្រោះច្រើនជាង គេអំពីជម្ងឺឆ្លង ជាពិសេសជនជាតិភាពតិចដែលរស់នៅតំបន់ព្រំដែនទាំងឡាយ ។

ក្នុងបណ្តារឆ្នាំថ្មីៗនេះ ប្រទេសទាំងបីបានឆ្លងកាត់កំណើនមេរោគហ៊ីវ/ជម្ងឺអេដស៍ និង និន្នាការរោគថ្លើមប្រភេទ C (ទោះបីជាការឆ្លងមេរោគអេដស៍នៅកម្ពុជាកំពុងថយចុះក្តី) និង ការផ្ទុះនៃជម្ងឺផ្លូវដង្ហើមធ្ងន់ធ្ងរ (SARS) ជម្ងឺគ្រុនបក្សី និង ជម្ងឺគ្រុនឈាម។ វិធីឆ្លងនៃជម្ងឺទាំងនេះតម្រូវឱ្យមានវិធានការតំបន់ ក្នុងលក្ខណៈសម្របសម្រួលគ្នាមួយចំពោះជម្ងឺទាំងនេះ។ ការឃ្លាំមើលជម្ងឺ និងសមត្ថភាពឆ្លើយតប ចាំបាច់ត្រូវការការពង្រឹងដែលផ្អែកលើបទប្បញ្ញត្តិ សុខាភិបាលអន្តរជាតិដែលត្រូវបានកែសម្រួលឡើងវិញរបស់អង្គការ WHO ដែលរំពឹងថា នឹងត្រូវបានអនុវត្តជាសកលនៅក្នុងឆ្នាំ ២០០៦។

គេឃើញមានប្រេវ៉ាឡង់មេរោគហ៊ីវ/ជម្ងឺអេដស៍ច្រើននៅក្នុងចំណោមប្រជាជនដែលមានហានិភ័យខ្ពស់ ហើយមេរោគហ៊ីវ/ជម្ងឺអេដស៍ កំពុងរីករាលដាលនៅក្នុងចំណោមប្រជាជននៅតាមស្ថាប័ន កម្មករទេសន្តរប្រវេសន៍ (និងប្រជាជនដែលប្រាស្រ័យទាក់ទងជាមួយនឹងកម្មករទេសន្តរប្រវេសន៍) និង ប្រជាជនដែលរស់នៅជិតផ្លូវ និង ទីផ្សារដែលទើប

កសាងក្នុងរយៈពេលថ្មីៗ។ ជាមួយនឹងកំណើនទូរគមនាគមន៍និងសុខុមាលភាព អកប្បកិរិយារបស់មនុស្សពេញវ័យកំពុងផ្លាស់ប្តូរយ៉ាងលឿន។ សុវត្ថិភាពឈាម គឺជាបញ្ហាដ៏ចំបងមួយនៅក្នុងតំបន់។ ខណៈដែលគេឃើញមានការផ្តល់មូលនិធិច្រើនសម្រាប់ការប្រយុទ្ធនឹងមេរោគហ៊ីវ/ជម្ងឺអេដស៍នៅក្នុងប្រទេសទាំងបី គេនៅឃើញមានគម្លាតដ៏ធំនៅក្នុងការផ្តល់មូលនិធិសម្រាប់ សកម្មភាពការពារទប់ស្កាត់។

ប្រជាជនដែលមានជម្ងឺឆ្លងកម្រិតខ្ពស់ច្រើនរស់នៅតាមទីកន្លែងដែលលទ្ធភាពចូលទៅដល់មានការលំបាក និង មានភាសាប្រពៃណី និង ទំនៀមទម្លាប់ដោយឡែកៗពីគ្នា ដែលតម្រូវឱ្យមានយុទ្ធសាស្ត្រពិសេស និងមានលក្ខណៈចម្រុះ។ យុទ្ធសាស្ត្រទាំងនេះ ក៏នឹងផ្តល់ផងដែរនូវ មូលដ្ឋានសម្រាប់ដោះស្រាយបញ្ហារួមផ្នែកសុខាភិបាល កង្វះអាហារូបត្ថម្ភ និងលទ្ធភាពមានកូនខ្ពស់ ដែលអាចមានផលប៉ះពាល់ច្រើនផងដែរលើស្ថានភាពនៃសុខភាព។ ការជួយសហគមន៍ទាំងនេះនឹងមានសារៈសំខាន់ចំពោះការសម្រេចបាននូវ MDGs។

ការត្រួតពិនិត្យជម្ងឺឆ្លងនឹងតម្រូវឱ្យមានការពិភាក្សាគោលនយោបាយកាន់តែខ្លាំងក្លាថែមទៀត។ មេរៀនដែលបានទទួលចាំបាច់ត្រូវចែករំលែកនៅក្នុងចំណោមប្រទេសមហាអនុតំបន់មេគង្គ (GMS) ដើម្បីកែលំអការរៀបចំប្រព័ន្ធសុខាភិបាល ធ្វើសុខុដុមនីយកម្មសេវាកម្មនិងកម្មវិធីទាំងឡាយ ហើយនិងកំណត់និយាមសម្រាប់ផលិតផលនិងសេវាកម្ម ទាំងឡាយ។ ឧទាហរណ៍ ថ្នាំពេទ្យដែលគ្មានប្រសិទ្ធិភាពសម្រាប់ជម្ងឺគ្រុនចាញ់និងរបេង ត្រូវបានប្រើប្រាស់ជាទូទៅតាមព្រំដែន ហើយការប្រើថ្នាំពេទ្យដោយគ្មានការត្រួតពិនិត្យ កំពុងបណ្តាលឱ្យមានបញ្ហាស៊ាំថ្នាំសម្រាប់ការព្យាបាលជម្ងឺរបេង និងគ្រុនចាញ់។

ស្របពេលជាមួយគ្នានេះ គេឃើញមានសនិទានភាពខ្លាំងក្លាចំពោះអភិក្រមប្រចាំតំបន់មួយដែលរួមមាន (១) ការសិក្សាពីអ្វីដែល មានប្រសិទ្ធិភាពនៅក្នុងកិច្ចអភិវឌ្ឍន៍ប្រព័ន្ធសុខាភិបាល ជាពិសេសវិធីជួយប្រជាជនដែលលទ្ធភាពចូលទៅដល់មានការលំបាក រួមទាំងជនជាតិ ភាគតិចផងដែរ (២) ការពង្រឹងប្រព័ន្ធឃ្លាំមើលនៅតាមព្រំដែន ដើម្បីដោះស្រាយហានិភ័យសុខាភិបាលនៃការរីករាលដាល ជម្ងឺថ្មី (៣) ការសម្របសម្រួលកម្មវិធីទប់ស្កាត់ជម្ងឺឆ្លង និង (៤) ការធ្វើស្តង់ដារកម្មលើផលិតផលនិងសេវាកម្មសុខាភិបាលនៅតាមព្រំដែន។ ការអភិវឌ្ឍន៍វិស័យទាំងនេះតម្រូវឱ្យមានការពង្រឹងស្ថាប័ន និង កិច្ចអភិវឌ្ឍន៍បច្ចេកវិទ្យាដែលនឹងទទួលអត្ថប្រយោជន៍ពីកិច្ចសហប្រតិបត្តិការក្នុងតំបន់។ គម្រោងនេះ នឹងផ្តោតការយកចិត្តទុកដាក់លើប្រជាពលរដ្ឋក្រីក្របំផុតក្នុងចំណោមប្រជាពលរដ្ឋក្រីក្រទាំងឡាយៈ ប្រសិនបើស្ថានភាពនៃសុខភាពរបស់សហគមន៍ដ៏ក្រីក្រខ្លាំងទាំងនេះមិនត្រូវបានកែលំអទេនោះ គោលដៅជាច្រើននៃ MDGs នៅក្នុង GMS នឹងមិនអាចសម្រេចបានឡើយ។ គម្រោងនេះ គឺស្របគ្នានឹងអាទិភាពទាំងឡាយដែលត្រូវបានកំណត់ដោយក្រុមការងារ GMS ស្តីពីកិច្ចអភិវឌ្ឍន៍ធនធាន មនុស្ស និង យុទ្ធសាស្ត្រនិងកម្មវិធីសហប្រតិបត្តិការ GMS។

ខ. **គោលដៅ និង គោលបំណងៈ** គោលបំណងនៃគម្រោងគឺដើម្បីជួយប្រទេសទាំងបីឱ្យសម្រេចបាននូវ MDGs របស់ខ្លួន

ជាពិសេស ចំពោះការទប់ស្កាត់ជម្ងឺឆ្លង និង ការស្លាប់របស់ម្តាយនិងកុមារ។ គោលដៅរួមមាន (១) ធានាឱ្យបាននូវការទប់ស្កាត់ឱ្យបានទាន់ពេលវេលានិងសមស្របនូវរោគរាតត្បាតទាំងឡាយ ដែលទំនងជានឹងមានផលប៉ះពាល់ខ្លាំងលើសុខភាពសាធារណៈនិងសេដ្ឋកិច្ចក្នុងតំបន់ (២) ទប់ស្កាត់ការរីករាលដាលនៃមេរោគហ៊ីវ/ជម្ងឺអេដស៍នៅក្នុងចំណោមប្រជាជនដែលស្ថិតក្នុងហានិភ័យ និង កែលំអសុវត្ថិភាពឈាម (៣) បន្ថយបន្ទុកនៃជម្ងឺឆ្លងរាលដាលនៅក្នុងចំណោមប្រជាពលរដ្ឋក្រីក្រ និង ស្ត្រីដែលរស់នៅក្នុងសហគមន៍ដាច់ស្រយាល (៤) ធ្វើសុខុដុមនីយកម្មស្តង់ដារសម្រាប់បុគ្គលិកនិងសេវាកម្មសុខាភិបាល និង គុណភាពនិងការប្រើថ្នាំពេទ្យ និង (៥) ពង្រឹងការរៀបចំប្រព័ន្ធសុខាភិបាលជាតិ។

គ. **សមាសភាគ និង សមិទ្ធិផល:** វិសាលភាពជាក់ស្តែងនៃគម្រោងនេះនឹងត្រូវកំណត់តាមរយៈ ជំនួយបច្ចេកទេស ត្រៀមរៀបចំគម្រោងមួយ។ គម្រោងនេះទំនងជានឹងមានសមាសភាគដូចខាងក្រោមនេះ: (១) ពង្រឹងប្រព័ន្ធឃ្លាំមើល និង ឆ្លើយតប ថ្នាក់ជាតិនិងតំបន់ ការត្រៀមខ្លួនចំពោះរោគរាតត្បាត និង ការអនុវត្តន៍បទប្បញ្ញត្តិសុខាភិបាល អន្តរជាតិដែលត្រូវបានកែ សម្រួលឡើងវិញរបស់អង្គការ WHO (២) កម្មវិធីអប់រំអំពីមេរោគអេដស៍/ជម្ងឺអេដស៍ និង ជម្ងឺឆ្លងផ្លូវភេទ (STI) នៅក្នុងចំណោមយុវជន ស្ត្រី កម្មករទេសន្តរប្រវេសន៍ ប្រជាជនដែលរស់នៅជិតផ្លូវ និង ទីផ្សារដែលទើបសង់ថ្មី និង ប្រជាជននៅតាមស្ថាប័នទាំងឡាយ (៣) ពង្រីកសេវាកម្ម និងកម្មវិធីឱ្យបានទៅដល់សហគមន៍ក្រីក្រដាច់ស្រយាល រួមទាំងជនជាតិភាគតិច និង ស្ត្រីដែលរស់នៅតាមតំបន់ព្រំដែន ដោយប្រើកញ្ចប់នៃសេវាកម្មសុខាភិបាលជាមូលដ្ឋាន (៤) ការគាំទ្រតាម តំបន់ដើម្បីកែលំអស្តង់ដារ និង គ្រប់គ្រងគុណភាពនៃ បុគ្គលិក សេវាកម្ម និង ថ្នាំពេទ្យ និង (៥) កិច្ចសហការក្នុងតំបន់ លើការវិភាគប្រព័ន្ធសុខាភិបាល ការប្រៀបធៀប កិច្ចអភិវឌ្ឍន៍គោលនយោបាយ និង ការអនុវត្តន៍គម្រោង។

ឃ. **លទ្ធផលរំពឹងទុក និង អាចសម្រេចបាន:** ការទប់ស្កាត់រោគរាតត្បាតឱ្យបានពីដំបូង ការពង្រឹងកម្មវិធីទប់ស្កាត់ជម្ងឺឆ្លង ការកាត់ បន្ថយប្រេវ៉ាឡង់នៃជម្ងឺឆ្លងធម្មតា និង ការកាត់បន្ថយការស្លាប់របស់កុមារ នៅក្នុងចំណោមប្រជាជនក្រីក្រខ្លាំង សហគមន៍ដែលលទ្ធភាពចូលទៅដល់មានការលំបាក ការផ្តល់អំណាចជូនស្ត្រី និង ការកែលំអស្ថានភាពនៃសុខាភិបាលនៅក្នុងទូទាំងប្រទេស។

ង. **បញ្ហាឬការបារម្ភខាងសង្គមកិច្ចនិងបរិស្ថាន:** មានតែផលប៉ះពាល់សង្គមជាវិជ្ជមានតែប៉ុណ្ណោះដែលត្រូវបានរំពឹងទុក។

ច. **ផែនការសម្រាប់ការផ្សព្វផ្សាយលទ្ធផល/សមិទ្ធិផល:** GMS និង អន្តរជាតិ តាមភាពសមស្របជាក់ស្តែង។

៧. **ស្ថាប័នប្រតិបត្តិ/អនុវត្តដែលត្រូវបានស្នើឡើង:**

ក្រសួងសុខាភិបាលនៃប្រទេសកម្ពុជា សាធារណៈរដ្ឋប្រជាធិបតេយ្យ ប្រជាមានិតឡាវ និងវៀតណាម។

**៨. ប្រភេទ/កម្រិតនៃការចូលរួមរបស់រដ្ឋាភិបាល/អ្នកទទួលផលប្រយោជន៍នៅក្នុងការកំណត់ឬការចាប់បដិសន្ធិជំនួយ:**

ភាគីពាក់ព័ន្ធជាច្រើននឹងត្រូវបានពិគ្រោះយោបល់ក្នុងអំឡុងពេលនៃការរៀបចំគម្រោង រួមទាំងស្ថាប័នរាជរដ្ឋាភិបាល NGOs ទីភ្នាក់ងារអន្តរជាតិ អង្គការមហាជន អាជ្ញាធរខេត្ត និង អ្នកទទួលផលប្រយោជន៍។

**៩. កាលវិភាគសម្រាប់ការរៀបចំគម្រោងជំនួយ ការពិនិត្យ និង ការអនុវត្តន៍:**

ក. ឆ្នាំដែលត្រូវបានដាក់បញ្ចូលក្នុង CSP, CSP ដែលបានធ្វើបច្ចុប្បន្នភាព, RCSP, RCSP ដែលបានធ្វើបច្ចុប្បន្នភាព ឬ ផែនការការងារអន្តរតំបន់: ឆ្នាំ ២០០៤

ខ. កាលបរិច្ឆេទរំពឹងនៃការដាក់សំណើសុំការឯកភាព

កម្ចីឥណទាន: ២០០៥

មិនមែនជាកម្ចីឥណទាន (ការត្រៀមរៀបចំគម្រោង): ២០០៤

មិនមែនជាកម្ចីឥណទាន (ក្រៅពីការត្រៀមរៀបចំគម្រោង):

គ. អំឡុងពេលនិងរយៈពេលនៃជំនួយ

កម្ចីឥណទាន: ២០០៥-២០១០

មិនមែនជាកម្ចីឥណទាន:

**១០. ផែនការហិរញ្ញប្បទាន**

ក. សម្រាប់ការផ្តល់កម្ចីឥណទាន

☐ ធនធានទុនធម្មតា:

☒ មូលនិធិអភិវឌ្ឍន៍អាស៊ី: ៣០ លានដុល្លារ (វៀតណាម ១៥ លានដុល្លារ កម្ពុជា ៩ លានដុល្លារ សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ៦ លានដុល្លារ)។

☐ ផ្សេងទៀត:

ខ. សម្រាប់គំរោងមិនមែនជាកម្ចីឥណទាន

☐ មិនចាំបាច់មានធនធានទេ ក្រៅតែពីបុគ្គលិក ADB

☐ ថវិការដ្ឋបាលរបស់ ADB:

☐ មូលនិធិជំនួយគ្មានសំណងបច្ចេកទេស

☐ ផ្សេងទៀត:

| ប្រភព | ចំនួន (លានដុល្លារ) |
|---|---|
| ហិរញ្ញប្បទាន ADB | |
| ហិរញ្ញប្បទានរដ្ឋាភិបាល | |
| WHO | |
| **ចំណាយសរុប** | |

ប្រភព: ការប៉ាន់ស្មានរបស់ ADB ។

ADB = ធនាគារអភិវឌ្ឍន៍អាស៊ី CSP = យុទ្ធសាស្ត្រនិងកម្មវិធីប្រចាំប្រទេស GMS = មហាអនុតំបន់មេគង្គ MDG = គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ RCSP = យុទ្ធសាស្ត្រនិងកម្មវិធីសហប្រតិបត្តិការប្រចាំតំបន់ SARS = ជម្ងឺផ្លូវដង្ហើមធ្ងន់ធ្ងរ STD = ជម្ងឺឆ្លងផ្លូវភេទ TA = ជំនួយបច្ចេកទេស WHO = អង្គការសុខភាពពិភពលោក ។

## តារាង ក៤.៥: គម្រោងកែលំអបរិស្ថាននៅចុងឃ្មាស

## ឯកសារគោលគំនិត

**កាលបរិច្ឆេទ:** ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២00៤

**១. ប្រភេទ/ទម្រង់នៃជំនួយ**

- ☐ ប្រភេទកម្ចីឥណទាន
  - ☒ ឥណទានគម្រោង
  - ☐ ឥណទានកម្មវិធីកំណែទម្រង់
  - ☒ ឥណទានវិស័យ
  - ☐ ឥណទានកម្មវិធីអភិវឌ្ឍន៍វិស័យ
  - ☐ ផ្សេងទៀត:
- ☐ ប្រភេទមិនមែនជាកម្ចីឥណទាន
  - ☐ សំរាប់ត្រៀមរៀបចំគម្រោង
  - ☐ ក្រៅពីសំរាប់ត្រៀមរៀបចំគម្រោង
    - ☐ ការងារផ្នែកសេដ្ឋកិច្ច ប្រធានបទ និង វិស័យ
    - ☐ កិច្ចអភិវឌ្ឍន៍ស្ថាប័ន
    - ☐ ផ្សេងទៀត:

**២. មុខព្រួញជំនួយ**

ក. ប្រសិនបើជំនួយផ្តោតលើវិស័យឬអនុវិស័យជាក់លាក់មួយ ចូរកំណត់

វិស័យ: កសិកម្មនិងធនធានធម្មជាតិ ដឹកជញ្ជូននិងគមនាគមន៍ ការផ្គត់ផ្គង់ទឹកនិងអនាម័យ និង ការគ្រប់គ្រងសម្រាម

អនុវិស័យ: បរិស្ថាននិងជីវៈចម្រុះ កំពង់ផែ ផ្លូវទឹក និង ការដឹកជញ្ជូនតាមកប៉ាល់ ការផ្គត់ផ្គង់ទឹក អនាម័យ និង ការគ្រប់គ្រងសម្រាម (ចម្រុះគ្នា)

ខ. សម្រាប់ការត្រៀមរៀបចំគម្រោងនិងការផ្តល់ឥណទាន ចំណាត់ថ្នាក់

☒ អន្តរាគមន៍មានមុខព្រួញ

☐ អន្តរាគមន៍ទូទៅ

គ. វិស័យប្រធានបទសំខាន់ៗ

ប្រធានបទ

☒ កំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព ☒ ចីរភាពបរិស្ថាន

☒ កិច្ចអភិវឌ្ឍន៍សង្គមរួម ☐ កិច្ចសហប្រតិបត្តិការតំបន់

☒ អភិបាលកិច្ច ☒ កិច្ចអភិវឌ្ឍន៍វិស័យឯកជន

☒ យេនឌ័រនិងកិច្ចអភិវឌ្ឍន៍

ប្រធានបទរង: ជម្រុញកិច្ចអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត ក្រុមងាយរងគ្រោះដទៃទៀត ការចូលរួមរបស់សង្គមស៊ីវិល សមធម៌យេនឌ័រនៅក្នុងការផ្តល់អំណាចនិងសិទ្ធិ ភាពជាដៃគូវិស័យសាធារណៈនិងឯកជន

**៣. វិសាលភាពគ្របដណ្តប់**

☒ ប្រទេស ☐ អនុតំបន់ ☐ អន្តរតំបន់

☐ កិច្ចអភិវឌ្ឍន៍គោលនយោបាយថ្នាក់ជាតិ

**៤. ផ្នែក/នាយកដ្ឋានទទួលបន្ទុក:** ផ្នែកវិស័យកសិកម្ម បរិស្ថាន និង ធនធានធម្មជាតិ/នាយកដ្ឋានមេគង្គ

**៥. មន្ត្រី ADB ទទួលបន្ទុក:** I. Fox ប្រធានអ្នកឯកទេសគម្រោង (ធនធានធម្មជាតិ)

**៦. ពិពណ៌នាអំពីជំនួយ**

ក. **សារៈតា/ការផ្សារភ្ជាប់ទៅនឹងយុទ្ធសាស្ត្រប្រចាំប្រទេស/តំបន់:** គម្រោងគ្រប់គ្រងបរិស្ថានបឹងទន្លេសាប (ឆ្នាំ ២០០២) មានបំណងបង្កើតការគ្រប់គ្រងនិងអភិរក្សប្រកបដោយចីរភាពលើធនធានធម្មជាតិនិងជីវៈចម្រុះនៅក្នុងអាងបឹងទន្លេ-សាប។ គម្រោងនេះក៏ផ្តួចផ្តើមផងដែរនូវក្របខ័ណ្ឌមួយ ដែលនៅក្នុងនោះ បណ្តាគម្រោងបន្ទាប់ទាំងឡាយនឹងដោះស្រាយការបារម្ភអំពីការគ្រប់គ្រងទូទៅនិងអភិរក្ស និង កែលំអស្ថានភាពសង្គមនិងបរិស្ថាន។ ហេដ្ឋារចនាសម្ព័ន្ធសម្រាប់ការគ្រប់គ្រងសម្រាម ការផ្គត់ផ្គង់ទឹក និង អនាម័យ ទីកន្លែងចូលចតទូកដែលមានគោលបំណងច្រើនទេសចរណ៍ធម្មជាតិ ហើយតំបន់រស់នៅកាន់តែល្អប្រសើរសម្រាប់សហគមន៍ក្រីក្រទាំងឡាយ នឹងត្រូវបានអភិវឌ្ឍជាតំណាក់កាលៗ ដែលជាផ្នែកមួយនៃយុទ្ធសាស្ត្ររាជរដ្ឋាភិបាលសម្រាប់អាងបឹងទន្លេសាប។ យុទ្ធសាស្ត្រនិងកម្មវិធីប្រចាំប្រទេសរបស់ (CSP) និង CSP ថ្មីឆ្លុះបញ្ចាំងអភិក្រមក្នុងទូទាំងវិស័យរបស់ ADB ចំពោះបឹងទន្លេសាប ដែល ADB

រំពឹងថានឹងអនុវត្តនៅក្នុងរយៈពេល ១០ ឆ្នាំ។

គម្រោងកែលំអរបរិស្ថាននៅចុងឃ្នាស គឺជាគំនិតផ្តួចផ្តើមមួយដែលមានគម្រោងការណ៍កែលំអរស្ថានភាពសង្គម និង បរិស្ថាន ជាផ្នែកមួយនៃយុទ្ធសាស្ត្ររួមសម្រាប់ការគ្រប់គ្រងបរិស្ថាននៃអាងបឹងទន្លេសាប។ គម្រោងនេះនឹងកសាងលើ ប្រព័ន្ធដែលត្រូវបានកែលំអសម្រាប់ការសម្របសម្រួលនិងការធ្វើផែនការគ្រប់គ្រងធនធានធម្មជាតិ ដែលកំពុងត្រូវបាន រៀបចំឡើងជាផ្នែកមួយនៃគម្រោងគ្រប់គ្រងបរិស្ថានបឹងទន្លេសាប។ ការកែលំអស្ថានភាពបរិស្ថាននិងការកាត់បន្ថយ ភាពក្រីក្រនៅចុងឃ្នាសគឺទាក់ទងគ្នា និង ត្រូវបានផ្សារភ្ជាប់យ៉ាងមាំទៅនឹងការកែលំអស្ថានភាពរស់នៅសម្រាប់ សហគមន៍នេះ។

យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ របស់រាជរដ្ឋាភិបាល (NPRS) ឆ្នាំ ២០០៣-២០០៥ និង ផែនការអភិវឌ្ឍន៍សង្គម សេដ្ឋកិច្ចប្រាំឆ្នាំលើកទីពីរ (SEDP II) ឆ្នាំ ២០០១-២០០៥ កំណត់យុទ្ធសាស្ត្រអភិវឌ្ឍន៍ និង កំណត់គោលដៅសម្រាប់ ការកាត់បន្ថយភាពក្រីក្រនៅជនបទ និង កែលំអអភិរក្សនិងការគ្រប់គ្រងធនធានធម្មជាតិ។ គោលដៅជាយុទ្ធសាស្ត្ររួម របស់ ADB នៅកម្ពុជា គឺការកាត់បន្ថយភាពក្រីក្រ ស្របគ្នាជាមួយនឹងកិច្ចព្រមព្រៀងលើភាពជាដៃគូរដើម្បីកាត់បន្ថយ ភាពក្រីក្ររវាងរាជរដ្ឋាភិបាល និង ADB។

គ. **គោលដៅ និង គោលបំណង:** គោលដៅនៃគម្រោងនេះគឺការគ្រប់គ្រងនិងអភិរក្សប្រកបដោយចីរភាពនូវធនធាន ធម្មជាតិនិងជីវៈចម្រុះនៅក្នុងអាងបឹងទន្លេសាប។ គោលបំណងនៃគម្រោងគឺដើម្បីកែលំអបរិស្ថានសង្គមនិងធម្មជាតិនៃ ចុងឃ្នាសនិងតំបន់នៅជុំវិញ។

ខ. **សមាសភាគ និង សមិទ្ធិផល :** គម្រោងនេះមានសមាសភាគចំនួនបី: (១) កិច្ចអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ (២) ការប្តូរ ទីលំនៅនិងជំនួយជីវភាពសម្រាប់សហគមន៍នៅចុងឃ្នាស និង (៣) ការបង្កើតអាជ្ញាធរកំពង់ផែចុងឃ្នាស (CKHA)។ ដើម្បីជួយ CKHA ក្នុងការគ្រប់គ្រងកំពង់ផែ និង បរិក្ខារឃុំដែលត្រូវបានផ្តល់ជូនក្រោមគម្រោងនេះ TA ផ្តល់ឱវាទ មួយនឹងអមគម្រោងនេះ។

ឃ. **លទ្ធផលរំពឹងទុក និង អាចសម្រេចបាន:** ក្រោមសមាសភាគ ១ ការសាងសង់នឹងត្រូវបានអនុវត្តដើម្បីបង្កើតប្រឡាយ នាវាចរ និងកំពង់ផែថ្មីមួយដែលទូកអាចចេញចូលបានពេញមួយឆ្នាំ។ កំពង់ផែនេះនឹងរួមមានកន្លែងផ្ទុកទំនិញ និង បរិក្ខារ ជញ្ជូនទំនិញចេញដាច់ពីគ្នាសម្រាប់ត្រី ទំនិញ ប្រេងឥន្ធនៈ និងអ្នកធ្វើដំណើរ រួមជាមួយនឹងកន្លែងសំចត សម្រាប់ដាក់ អ្នកដំណើរ ទំនិញ និង ទូកនេសាទនៅចុងឃ្នាស។ បច្ចុប្បន្ននេះ ឃុំថ្មីមួយនៅលើទីតាំងមិនលេចទឹកមួយ (សាងសង់ពី ការចាក់ដីបំពេញ) នឹងត្រូវបានបង្កើតឡើង និង ត្រូវបានបំពាក់ដោយលំនៅស្ថាន ទឹកផឹក អនាម័យ ផ្លូវ

និងដីគ្រប់គ្រាន់សម្រាប់សាលារៀន មន្ទីរព្យាបាលរោគ និងហេដ្ឋារចនាសម្ព័ន្ធសង្គមផ្សេងទៀត។ សមាសភាគ ២ នឹងជួយសហគមន៍ចុងឃ្នាសឱ្យធ្វើការឈានចេញពីការតាំងលំនៅស្ថានលើទឹកទៅកាន់ការតាំងលំនៅស្ថានលើដីវិញ។ សមាសភាគនេះ នឹងធានាឱ្យបានថា មានសំណងជួសជុលការខូចខាត និងជំនួយគ្រប់គ្រាន់ចំពោះជីវភាពក្នុងរយៈពេលនៃដំណើរការប្តូរទីលំនៅ និងអភិវឌ្ឍ (ដោយមានការពិគ្រោះយោបល់ដ៏ជិតស្និទ្ធជាមួយសហគមន៍ដែលរងផលប៉ះពាល់) នូវកាលានុវត្តភាពជីវភាពល្អប្រសើរ។ មធ្យោបាយជាក់លាក់សម្រាប់ធានាឱ្យបាននូវលទ្ធភាពប្រើប្រាស់បរិក្ខារគម្រោង និងលទ្ធភាពទទួលអត្ថប្រយោជន៍គម្រោង នឹងត្រូវបានដាក់បញ្ចូល។ TA ផ្តល់ឱវាទ នឹងបង្កើតក្របខ័ណ្ឌសម្រាប់កំណែទម្រង់បទប្បញ្ញត្តិ និងកំណែទម្រង់ស្ថាប័នដើម្បីអនុញ្ញាតឱ្យមានការបង្កើត CKHA អភិវឌ្ឍរចនាសម្ព័ន្ធស្ថាប័នសមស្របសម្រាប់ CKHA និងផ្តល់អនុសាសន៍សំដៅធានាឱ្យបាននូវលទ្ធភាពឋិតថេរបានខាងហិរញ្ញវត្ថុនៃ CKHA។ ផែនការសកម្មភាពកសាងសមត្ថភាពមួយ នឹងត្រូវបានរៀបចំឡើង រួមទាំងវិធានការបណ្តោះអាសន្នដើម្បីអនុញ្ញាតឱ្យមានប្រតិបត្តិការប្រកបដោយប្រសិទ្ធិភាពក្នុងអំឡុងពេលនៃការអនុវត្តន៍គម្រោង។

ង. **បញ្ហាឬការបារម្ភខាងសង្គមកិច្ចនិងបរិស្ថាន:** ចុងឃ្នាស និងតំបន់ជុំវិញត្រូវបានប្រើប្រាស់ដោយសហគមន៍ក្រីក្របណ្តែតទឹកនិងនៅលើដី ដែលរងទុក្ខដោយភាពក្រីក្រកម្រិតខ្ពស់: ប្រជាជនប្រមាណជា ៦០% រស់លើប្រាក់ចំណូលតិចជាង ០,៥០ ដុល្លារក្នុងមួយនាក់ក្នុងមួយថ្ងៃ។ សហគមន៍នេះរងទុក្ខដោយកង្វះលទ្ធភាពទទួលហេដ្ឋារចនាសម្ព័ន្ធនិងសេវាកម្មសង្គមជាមូលដ្ឋាន។ ភាពក្រីក្រនៃសហគមន៍នេះគឺមានទំនាក់ទំនងយ៉ាងខ្លាំងជាមួយនឹងស្ថានភាពបរិស្ថានដ៏អាក្រក់ ប្រាក់ចំណូលទាប លំនៅស្ថានមិនល្អ កង្វះសេវាកម្មសង្គមគ្រប់គ្រាន់ មូលដ្ឋានដែលមានធនធានកាន់តែខ្សត់ឡើង និង កង្វះទីផ្សារ។ ក្នុងការឈានចេញពីភូមិបណ្តែតទឹករបស់ខ្លួនទៅកាន់ការតាំងលំនៅស្ថានលើដីមិនលិចទឹកវិញ សហគមន៍នេះសង្ឃឹមថា បរិស្ថានដែលបានស្នើឡើងនៅចុងឃ្នាសនឹងនាំមកនូវកាលានុវត្តភាពប្រាក់ចំណូលល្អប្រសើរជាងដែលត្រូវបានអមមកជាមួយនូវលទ្ធភាពកាន់តែប្រសើរឡើងក្នុងការទទួលសេវាកម្មចាំបាច់ទាំងឡាយ ដូចជាការអប់រំ និងបរិក្ខារសុខាភិបាល។ ជនជាតិភាគតិច ជាពិសេស ជនជាតិភាគតិចដើមកំណើតវៀតណាម គឺងាយរងគ្រោះដោយភាពឯកកោក្នុងសង្គម និងចំពោះការមិនបានរួមបញ្ចូលក្នុងការផ្តល់សេវាកម្ម។ គម្រោងនេះ នឹងធានាឱ្យបានថា ប្រព្រឹត្តិកម្មស្មើភាពគ្នាត្រូវបានផ្តល់ជូនដល់សហគមន៍វៀតណាមដែលបានកើតនៅកម្ពុជា និងដែលរស់នៅនិងធ្វើការងារនៅចុងឃ្នាសចំពោះការចូលរួមដ៏ពេញលេញនិងលទ្ធភាពរបស់ពួកគេក្នុងការទទួលអត្ថប្រយោជន៍គម្រោង។ ជីវភាព ជាជម្រើសផ្សេងៗនឹងត្រូវបានកំណត់ ហើយជំនួយនឹងត្រូវបានផ្តល់ជូនសម្រាប់ពិពិធកម្មប្រាក់ចំណូល។ ការបង្កើតរចនាសម្ព័ន្ធអំណាចនឹងត្រូវបានបានវាយតម្លៃយ៉ាងប្រុងប្រយ័ត្ន ហើយសកម្មភាពស្ថាប័នថ្មីៗ នឹងត្រូវបានរៀបចំឡើងដោយការពិគ្រោះយោបល់ ដ៏ជិតស្និទ្ធជាមួយសហគមន៍ និង តំណាងរបស់សហគមន៍។

ច. **ផែនការសម្រាប់ផ្សព្វផ្សាយលទ្ធផល និង សមិទ្ធិផល:** សិក្ខាសាលានឹងត្រូវបានធ្វើឡើងនៅតាមចំណុចសម្រេចចិត្ត

សំខាន់ៗទាំងឡាយក្នុងរយៈពេលដំណើរការគម្រោង។ NGOs នឹងត្រូវបានជួលឱ្យគៀងគរសហគមន៍ទាំងឡាយ និង ឱ្យជួយនៅក្នុងគំនិតផ្តួចផ្តើមកាត់បន្ថយភាពក្រីក្រ និង ក្នុងការផ្តល់ជំនួយសម្រាប់កិច្ចអភិវឌ្ឍន៍ជីវភាពជាជម្រើស។

៧. **ស្ថាប័នប្រតិបត្តិ/អនុវត្តដែលត្រូវបានស្នើឡើង:** ក្រសួងសាធារណៈការនិងដឹកជញ្ជូន (MPWT) នឹងគឺជាក្រសួងប្រតិបត្តិ។ គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា (CNMC) នឹងដឹកនាំគណៈកម្មាធិការដឹកនាំមួយដើម្បីគ្រប់គ្រងការអនុវត្តន៍គម្រោង និង ចាត់ចែងការទទួលខុសត្រូវរបស់កម្ពុជាតាមកិច្ចព្រមព្រៀងទន្លេមេគង្គ។ ក្រសួងមហាផ្ទៃ ក្រសួងកិច្ចការនារី ក្រសួងបរិស្ថាន ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ និង ក្រសួងដែនដី នគរូបនីយកម្មនិងសំណង់ នឹងមានតំណាងនៅក្នុងគណៈកម្មាធិការដឹកនាំនេះ។

៨. **ប្រភេទ/កម្រិតនៃការចូលរួមរបស់រដ្ឋាភិបាល/អ្នកទទួលផលប្រយោជន៍នៅក្នុងការកំណត់ឬការចាប់បដិសន្ធិជំនួយ:** យុទ្ធសាស្ត្រអភិវឌ្ឍន៍ផ្អែកលើធនធានធម្មជាតិមួយសម្រាប់តំបន់បឹងទន្លេសាប ត្រូវបានរៀបចំឡើងនៅក្នុងឆ្នាំ ១៩៩៨ ដោយលេខាធិការនៃគណៈកម្មការទន្លេមេគង្គ ដោយសហប្រតិបត្តិការជាមួយកម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ។ ក្រោម REG-5822 (ការការពារនិងការគ្រប់គ្រងតំបន់សើមសំខាន់ៗទាំងឡាយនៅក្នុងអាងទន្លេមេគង្គខាងក្រោម) ដែលត្រូវបានអនុម័តនៅថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ១៩៩៨ ADB បានគាំទ្រការធ្វើអង្កេតសង្គមសេដ្ឋកិច្ច និង ការពិគ្រោះយោបល់ជាច្រើនជាមួយនឹងសហគមន៍ក្នុងមូលដ្ឋាន និង តំណាងរដ្ឋាភិបាល លើការអភិវឌ្ឍន៍កំពង់ផែ និង ការកែលំអបរិស្ថាន។ ក្រោម TA-3997-CAM (គម្រោងកែលំអបរិស្ថាននៅចុងឃ្នាស) អង្កេតសង្គមនិងការពិគ្រោះយោបល់បន្ថែមទៀតត្រូវបានធ្វើឡើង។ NGOs ជាច្រើនចូលរួមយ៉ាងសកម្មនៅក្នុងការកែលំអសេវាកម្មសង្គមនៅក្នុងតំបន់គម្រោង។ ក្រោមគម្រោងនេះ គេនឹងមានផ្តល់ការចូលរួមពេញលេញចំពោះក្រុមងាយរងគ្រោះនៃសហគមន៍ទាំងឡាយដែលទទួលផលប៉ះពាល់ ដូចជាគ្រួសារដែលមានមេគ្រួសារជាស្ត្រីជាដើម។

៩. **កាលវិភាគសម្រាប់សំរាប់ការរៀបចំគម្រោងជំនួយ ការពិនិត្យ និង ការអនុវត្តន៍:**

ក. ឆ្នាំដែលត្រូវបានដាក់បញ្ចូលក្នុង CSP, CSP ថ្មី, RCSP, RCSP ថ្មី ឬ ផែនការការងារអន្តរតំបន់: ឆ្នាំ ២០០៣

ខ. កាលបរិច្ឆេទរំពឹងនៃការដាក់សំណើសុំការឯកភាព

កម្ចីឥណទាន: ២០០៥

មិនមែនជាកម្ចីឥណទាន (ការត្រៀមរៀបចំគម្រោង): ២០០៤

មិនមែនជាកម្ចីឥណទាន (ក្រៅពីការត្រៀមរៀបចំគម្រោង): ២០០៥ (អម ADT សម្រាប់ CKHA)

គ. អំឡុងពេលនិងរយៈពេលនៃជំនួយ

កម្ចីឥណទាន: ២០០៦-២០១២

មិនមែនជាកម្ចីឥណទាន: ២០០៦-២០០៨ (២៤ ខែ)

## ១០. ផែនការហិរញ្ញប្បទាន

ក. សម្រាប់ការផ្តល់កម្ចីឥណទាន

☐ ធនធានទុនធម្មតា:

☒ មូលនិធិអភិវឌ្ឍន៍អាស៊ី: ១៥ លានដុល្លារ ។

☒ ផ្សេងទៀត: ៦ លានដុល្លារសម្រាប់លំនៅស្ថាន និង សេវាកម្ម (ប្រភពមិនទាន់បានកំណត់)

ប្រសិនបើចាំបាច់មានហិរញ្ញប្បទានរួម ចូរបង្ហាញចំនួននិងប្រភពដែលសុំ: ៦ លានដុល្លារ ពី (ប្រភពមិនទាន់បានកំណត់) ។
ប្រសិនបើដឹងប្រភព ចូរផ្តល់ការប៉ាន់ស្មានចំណាយ និង កិច្ចព្រមព្រៀងហិរញ្ញប្បទាន ។

| ប្រភព | ចំនួន (លានដុល្លារ) |
|---|---|
| ហិរញ្ញប្បទាន ADB | ១៥,០ |
| ហិរញ្ញប្បទានរដ្ឋាភិបាល | ៥,០ |
| ហិរញ្ញប្បទានផ្សេងទៀត | ៦,០ |
| **ចំណាយសរុប** | **២៦,០** |

ប្រភព: ការប៉ាន់ស្មានរបស់ ADB ។

ខ. សម្រាប់ការមិនផ្តល់កម្ចីឥណទាន

☐ មិនចាំបាច់មានធនធានទេ ក្រៅតែពីបុគ្គលិក ADB

☐ ថវិការដ្ឋបាលរបស់ ADB:

☐ មូលនិធិជំនួយគ្មានសំណងបច្ចេកទេស

☐ ផ្សេងទៀត: ៦០០.០០០ ដុល្លារ

ប្រសិនបើចាំបាច់មានហិរញ្ញប្បទានរួម ចូរបង្ហាញចំនួននិងប្រភពដែលស្នើសុំ: ៦00.000 ដុល្លារ ពី (រដ្ឋាភិបាលប្រទេសហ្វាំងឡង់)។ ប្រសិនបើដឹងប្រភព ចូរផ្តល់ការប៉ាន់ស្មានចំណាយ និង កិច្ចព្រមព្រៀងហិរញ្ញប្បទាន។

| **ប្រភព** | **ចំនួន (លានដុល្លារ)** |
| --- | --- |
| ហិរញ្ញប្បទាន ADB | |
| ហិរញ្ញប្បទានរដ្ឋាភិបាល | |
| ហិរញ្ញប្បទានផ្សេងទៀត | |
| **ចំណាយសរុប** | |

ប្រភព: ការប៉ាន់ស្មានរបស់ ADB ។

ADB = ធនាគារអភិវឌ្ឍន៍អាស៊ី CSP = យុទ្ធសាស្ត្រនិងកម្មវិធីប្រចាំប្រទេស RCSP = យុទ្ធសាស្ត្រនិងកម្មវិធីសហប្រតិបត្តិការប្រចាំតំបន់ TA = ជំនួយបច្ចេកទេស។